# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៣ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការប្តូរឈ្មោះ សាកលវិទ្យាល័យញូវតុនធីឡាយ ទៅជា សាកលវិទ្យាល័យសុវណ្ណភូមិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៤ ស្តីពីការទទួលស្គាល់សាកលវិទ្យាល័យញូវតុនធីឡាយ
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និងកីឡា តាមលិខិតលេខ ៩៩១ អយក.ឧស ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៧

## ស ម្រេ ច

**មាត្រា ១ :** ទទួលស្គាល់ការប្តូរឈ្មោះ ***សាកលវិទ្យាល័យពុទ្ធសាស្ត្រ*** ទៅជា ***សាកលវិទ្យាល័យសុវណ្ណភូមិ*** " SOVANNAPHUMI UNIVERSITY " ហៅកាត់ជាភាសាខ្មែរ " ស.ស.ភ " និងហៅកាត់ជាភាសាអង់គ្លេស " SPU " ។ សាកលវិទ្យាល័យនេះ មានទីតាំងស្ថិតនៅអគារលេខ ១៣១ ផ្លូវលេខ ១៤៣ កែងផ្លូវលេខ ៣៦៨ សង្កាត់បឹងកេងកង ៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**មាត្រា ២ :** សាកលវិទ្យាល័យសុវណ្ណភូមិ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៣ :** សាកលវិទ្យាល័យសុវណ្ណភូមិ មានភារកិច្ច :

- បណ្តុះបណ្តាលអ្នកជំនាញឯកទេសឧត្តមសិក្សាគ្រប់កម្រិត ស្របតាមបេសកកម្មរបស់ សាកលវិទ្យាល័យ
- បង្កើនសមត្ថភាពមុខជំនាញបច្ចេកទេសដល់គ្រូបង្រៀន និងសាស្ត្រាចារ្យ សម្រាប់សាកលវិទ្យាល័យសុវណ្ណភូមិ
- រៀបចំកម្មវិធីសិក្សា ឱ្យស្របតាមតម្រូវការទីផ្សារការងារ ស្តង់ដារអន្តរជាតិ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា
- សិក្សាស្រាវជ្រាវខ្លឹមសារនៃការសិក្សា វិធីសាស្ត្របង្រៀន និងចងក្រងឯកសារបច្ចេកទេសវិទ្យាសាស្ត្រជាភាសាជាតិ និងភាសាបរទេស ឱ្យបានសមស្របសម្រាប់ប្រើប្រាស់
- រៀបចំ និងដំណើរការជ្រើសរើសនិស្សិតឱ្យចូលរៀន ប្រឡងចេញ និងស្វ័យវាយតម្លៃលើការសិក្សាឱ្យបានត្រឹមត្រូវ តាមគោលការណ៍ និងប្រកបដោយតម្លាភាព
- ធ្វើការស្រាវជ្រាវវិទ្យាសាស្ត្រ តាមឯកទេសរបស់សាកលវិទ្យាល័យសុវណ្ណភូមិ
- កសាងផែនការអភិវឌ្ឍ សម្រាប់សាកលវិទ្យាល័យសុវណ្ណភូមិ
- គ្រប់គ្រងនិយោជិក កម្មករ និស្សិត សាស្ត្រាចារ្យ និងទ្រព្យសម្បត្តិរបស់ សាកលវិទ្យាល័យសុវណ្ណភូមិ
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័ននានា ក្នុងគោលបំណងធ្វើឱ្យកាន់តែល្អប្រសើរឡើងនូវការសិក្សា ការបង្រៀន និងការស្រាវជ្រាវ ។

**មាត្រា ៤ :** សាកលវិទ្យាល័យសុវណ្ណភូមិ ធ្វើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត ដែលរចនាសម្ព័ន្ធសិក្សាត្រូវបានរៀបចំ ឱ្យមានមហាវិទ្យាល័យប្រាំ :

- មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសា
- មហាវិទ្យាល័យគណិតសាស្ត្រ និងវិទ្យាសាស្ត្រ
- មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម និងសេដ្ឋកិច្ច
- មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍
- មហាវិទ្យាល័យព័ត៌មានវិទ្យា និងទូរគមនាគមន៍

ទៅអនាគត សាកលវិទ្យាល័យសុវណ្ណភូមិ អាចប្តូរឈ្មោះ ប្តូរទីតាំង ពង្រីកទីតាំង ធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងគ្រឹះស្ថានឧត្តមសិក្សាបរទេស ឬបើកមហាវិទ្យាល័យ សាខា ឯកទេស ឬប្រភេទអប់រំដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពី ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៥ :** សាកលវិទ្យាល័យសុវណ្ណភូមិ មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេច លើគោលនយោបាយ ផែនការអភិវឌ្ឍសាកលវិទ្យាល័យ និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត ។

**មាត្រា ៦ :** តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែង នៃសាកលវិទ្យាល័យសុវណ្ណភូមិ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលរបស់សាកលវិទ្យាល័យ និងដោយមានការឯកភាពពី ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៧ :** សាកលវិទ្យាល័យសុវណ្ណភូមិ ត្រូវគ្រប់គ្រងដោយសាកលវិទ្យាធិការមួយរូប ដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៨ :** សាកលវិទ្យាធិការ មានភារកិច្ច :

- ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យសុវណ្ណភូមិ
- រៀបចំផែនការយុទ្ធសាស្ត្រ សម្រាប់អភិវឌ្ឍន៍សាកលវិទ្យាល័យសុវណ្ណភូមិ
- ទទួលបន្ទុកអនុវត្តបទដ្ឋានទាំងឡាយរបស់រាជរដ្ឋាភិបាល និងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលពាក់ព័ន្ធទៅនឹងការងារបណ្តុះបណ្តាល
- ធ្វើរបាយការណ៍គ្រប់គ្រងប្រចាំឆមាស ប្រចាំឆ្នាំ និងសកម្មភាពផ្សេងៗទៀត ជូនក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់
- កំណត់ការរៀបចំរចនាសម្ព័ន្ធ និងភារកិច្ច ដល់អង្គភាពនានាក្រោមឱវាទ
- បំពេញតួនាទីតាមឋានានុក្រម ចំពោះបុគ្គលិកទាំងអស់របស់សាកលវិទ្យាល័យសុវណ្ណភូមិ និងគោរពតាមវិធានការ ស្តីពីការគ្រប់គ្រងបុគ្គលិក
- កំណោះបទបញ្ហាផ្ទៃក្នុង នៃសាកលវិទ្យាល័យសុវណ្ណភូមិ
- ត្រូវធានាឱ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម
- ជាតំណាងរបស់សាកលវិទ្យាល័យ ក្នុងការទំនាក់ទំនងជាមួយតតិយជន ។

**មាត្រា ៩ :** និស្សិតដែលបានរៀនចប់កម្មវិធីសិក្សារបស់សាកលវិទ្យាល័យសុវណ្ណភូមិ និងទទួលបានជោគជ័យ ក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងតាមឯកទេសដែលបានសិក្សា។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយសាកលវិទ្យាល័យសុវណ្ណភូមិ ហើយមានការទទួលស្គាល់ពី ក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីសាកលវិទ្យាល័យនេះ បំពេញ និងអនុវត្តបានតាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ១០ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១១ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាកលវិទ្យាល័យសុវណ្ណភូមិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- សាលាក្រុងភ្នំពេញ
- ដូចមាត្រា ១១
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ